សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# កិច្ចការស្រាវជ្រាវ

# ការទប់ស្កាត់ការចូលកាន់កាប់ដីខុសច្បាប់ នៅកម្ពុជា

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ

-**ចូវ រតនា**

-**លី សុជាតា**

-**អ៊ុក យ៉ាលីនីត**

-**ម៉ី ពុធមករា**

-**លាង មុន្នីរ័ត្ន**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ហាប់ ផល្លី**

ថ្នាក់ **បរិញ្ញាបត្រជាន់ខ្ពស់ នីតិសាស្ត្រ**

ជំនាញ **នីតិឯកជន** ជំនាន់ទី១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរកិច្ចការស្រាវជ្រាវ ២០១៣

**រក្សាសិទ្ធិដោយ** Khmer Famous

# មាតិកា


សេចក្តីផ្តើម ........................................ 1

ផ្នែកទី១ ការកាន់កាប់ដីខុសច្បាប់ ........................................ 2

កថាខណ្ឌទី១ ការកាន់កាប់ដីឯកជនស្របច្បាប់ ........................................ 2

កថាខណ្ឌទី២ ការកាន់កាប់ដីរដ្ឋ ........................................ 2

ផ្នែកទី២ វិធានការទប់ស្កាត់ការកាន់កាប់ដីខុសច្បាប់ ........................................ 3

កថាខណ្ឌទី១ ការដកហូតដីរដ្ឋមកវិញ ........................................ 3

កថាខណ្ឌទី២ ការចុះបញ្ជីដី ........................................ 4

អនុសាសន៍ ........................................ 6

គន្ថនិទ្ទេស ........................................ 7

# សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានវ័យចំណាស់យូរណាស់មកហើយ ហើយក៏ជាប្រទេសមួយដែរ ដែលធ្លាប់ជួបការលំបាក ទុក្ខវេទនា ក្នុងភ្លើងសង្គ្រាម អស់រយៈកាលច្រើនសតវត្សរ៍កន្លងមក។ លុះរហូតមកដល់បច្ចុប្បន្ននេះ ក្រោយពីប្រទេសកម្ពុជា បានរួចផុតពីសង្គ្រាមរ៉ាំរ៉ៃមួយរយៈមកនេះ ប្រទេសកម្ពុជាក៏ប្រែក្លាយមុខមាត់ថ្មី ដោយធ្វើការអភិវឌ្ឍន៍ពង្រឹងខ្លួនឯងជាច្រើនវិស័យគ្រប់ជាន់ថ្នាក់ និងគ្រប់តំបន់ និង បានវិវត្តន៍ពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែរីកចំរើនឡើងជាលំដាប់ ដែលធ្វើឲ្យមនុស្សសព្វថ្ងៃ ក៏កាន់តែមានភាពស៊ីវិល័យផងដែរ។ យ៉ាងណាមិញ រដ្ឋាភិបាលរបស់ប្រទេសកម្ពុជាដែលបង្កើតឡើងតាមឆន្ទៈរបស់ប្រជាពលរដ្ឋ បានខំប្រឹងប្រែងកសាងប្រទេសឲ្យកាន់តែរីកដុះដាល ខិតខំបំរើឲ្យដល់ប្រជាជនទូទាំងប្រទេស ធ្វើយ៉ាងណាឲ្យមានសមភាពរវាងគ្នានិងគ្នាក្នុងលទ្ធិប្រជាធិបតេយ្យ ជាពិសេសនោះ គឺសិទ្ធិដែលម្នាក់ៗមានតាំងពីកំណើត តែសិទ្ធិនេះស្ថិតនៅក្នុងព្រំដែនមួយដែលបានកំណត់នៅក្នុងច្បាប់។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានលើកឡើងនូវគោលនយោបាយមួយដោយប្រគល់ឲ្យប្រជាជនរបស់ខ្លួនទទួលបាននូវសិទ្ធិក្នុងការទទួលបានកម្មសិទ្ធិស្របច្បាប់ពីស្ថាប័នរដ្ឋ ទាំងលើចលនវត្ថុ និង អចលនវត្ថុ ប៉ុន្តែទ្រព្យមួយចំនួនក៏បានរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ។ ដោយសារតែ មានប្រជាជនមួយចំនួន នៅតែចង់មានចង់បាន ក៏មានចិត្តលោភលន់ចង់ក្តោបក្តាប់នូវកម្មសិទ្ធិរបស់អ្នកដំទៃ ក៏ដូចជាទ្រព្យសម្បត្តិរដ្ឋ ឬ ក៏កម្មសិទ្ធិឯកជនមកធ្វើជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន ក៏បានរំលោភបំពាន ទន្រ្ទានយកអចលវត្ថុរបស់រដ្ឋ និង ទ្រព្យអ្នកដំទៃថែមទៀត។ ហេតុនេះហើយ ក៏មានប្រធានបទ ស្តីពី **ការទប់ស្កាត់ការចូលកាន់កាប់ដីខុសច្បាប់** លើកឡើងយកមកធ្វើការសិក្សាស្រាវជ្រាវទាំងទៅលើការកាន់កាប់ដីរបស់រដ្ឋ និង ការកាន់កាប់ដីឯកជន របស់សិស្សនិស្សិត ដើម្បីស្វែងយល់ឲ្យបានច្រើនពីបញ្ហានេះ ថាតើច្បាប់ ក៏ដូចជា រដ្ឋ មានដំណោះស្រាយ និង បានអនុវត្តវិធានការណ៍បែបណាក្នុងការចៀសវាងកុំឲ្យមានបញ្ហានេះកើតឡើងមានតទៅទៀត។ ដោយការសិក្សានេះ រួមមាន ការកាន់កាប់ដីខុសច្បាប់ (ផ្នែកទី១) និង វិធានការទប់ស្កាត់ការចូលកាន់កាប់ដីខុសច្បាប់ (ផ្នែកទី២)។

## ផ្នែកទី១ ការកាន់កាប់ដីខុសច្បាប់

### កថាខណ្ឌទី១ ការកាន់កាប់ដីឯកជនស្របច្បាប់

បុគ្គលទាំងឡាយដែលបានអាស្រ័យផល នៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ឆ្នាំ យ៉ាងតិច គិតមកដល់កាលបរិច្ឆេទ នៃការប្រកាសឲ្យប្រើច្បាប់ភូមិបាល លើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវ តាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំ ប័ណ្ណកម្មសិទ្ធិស្ថាពរ។[1]

ដើម្បីក្លាយជាកម្មសិទ្ធិលើអចលនវត្ថុបាន លុះត្រាតែភោគៈនោះត្រូវបានកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សា ដឹងលឺជាសាធារណៈ គ្មានអាក់ខាន និងដោយសុចរិត។[2]

*<u>សំគាល់:</u> ទោះបីជាយ៉ាងណា លក្ខខណ្ឌទាំងនេះ ត្រូវបានយកមកអនុវត្តក្នុងការទទួលបានកម្មសិទ្ធិភោគៈ តែបើទ្រព្យសម្បត្តិនោះជាទ្រព្យសម្បត្តិរបស់រដ្ឋ មិនអាចឋិតនៅក្រោមការកាន់កាប់ដោយលទ្ធកម្មពិសេសទេ។[3]*

*ក្រោយពីច្បាប់ភូមិបាល ឆ្នាំ ២០០១ ចូលជាធរមាន គឺគ្មានកាប់យកដីតាមទំនើងចិត្តណាមួយអាចកើតឡើងទៅលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ឬ របស់នីតិបុគ្គលសាធារណៈបានឡើយ។[4]*

អចលនវត្ថុទាំងឡាយដែលមិនអាចក្លាយជាកម្មសិទ្ធិស្របទៅតាមច្បាប់ គឺ ក្នុងករណីដែលភោគីមិនបានបំពេញនូវលក្ខខណ្ឌនៃច្បាប់ដោយហេតុមកពីលក្ខណសម្បត្តិរបស់ភោគីនោះជាភោគីគេងបន្លំ ឬ ដោយឥរិយាបថរបស់ខ្លួនជាភោគីដែលលួចលាក់នឹងច្បាប់ ឬ ដែលមិនចេញមុខ ឬ ជាភោគីដោយប្រើហិង្សា។[5]

### កថាខណ្ឌទី២ ការកាន់កាប់ដីរដ្ឋ

ដោយឃើញថា ក្រោយពីច្បាប់ភូមិបាល ឆ្នាំ ២០០១ បានចូលជាធរមាន ការចូលកាន់កាប់ដីតាមរូបភាពភោគៈនោះ គឺត្រូវបានបញ្ចប់ ក្នុងពេលដែលរដ្ឋពុំទាន់មានវិធានការអនុវត្តឲ្យទូលំទូលាយនូវកម្មវិធីសម្បទានដីសង្គមកិច្ចសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ ក្នុងគោលបំណងដោះស្រាយសេចក្តីត្រូវការដីរបស់ពលរដ្ឋ និង ចេះតែកើនឡើងជារៀងរាល់ថ្ងៃ ដោយមូលហេតុកំណើនប្រជាជន ការរំសាយកងទ័ព ការបាត់បង់ដីដោយសារគ្រោះធម្មជាតិ ដែលនេះហើយធ្វើឲ្យប្រជាជនចូលកាន់កាប់ដីរដ្ឋដោយអនាធិបតេយ្យ រួមទាំងជនឆ្លៀតឱកាសមួយចំនួនចូលកាន់កាប់ដី

---

[1] មាត្រា ៣០ ច្បាប់ភូមិបាល ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១

[2] មាត្រា ៣៨ ច្បាប់ភូមិបាល ឆ្នាំ ២០០១

[3] មាត្រា ១៦ ច្បាប់ភូមិបាល វាក្យខណ្ឌ២ ឆ្នាំ ២០០១

[4] មាត្រា ១៧ ច្បាប់ភូមិបាល វាក្យខណ្ឌ ៣ ឆ្នាំ ២០០១

[5] មាត្រា ៣២ នៃច្បាប់ភូមិបាល ឆ្នាំ ២០០១

រដ្ឋខុសនឹងច្បាប់តាមរូបភាពផ្សេងៗ។ ដូចនេះហើយ ច្បាប់ក៏បានបង្កើតនូវគោលការណ៍ និង ការកំណត់មួយចំនួនដែលចាត់ទុកថាជាកាន់កាប់ដីរដ្ឋដោយខុសច្បាប់៖

–រាល់ការចូលកាន់កាប់ដីរដ្ឋ (ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ) ជាភោគៈក្រោយច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន

–រាល់ការកាន់កាប់ដីរដ្ឋជាភោគៈ នៅលើដីដែលបានកំណត់រួចហើយ ជាដីសាធារណៈរបស់រដ្ឋ ទោះជាមុន ឬ ក្រោយច្បាប់ភូមិបាលចូលជាធរមានក៏ដោយ

–រាល់ការបន្តកាន់កាប់ដីរដ្ឋ ក្រោយពេលលិខិតអនុញ្ញាត ឬ កិច្ចសន្យាឲ្យប្រើប្រាស់ដីរដ្ឋអស់សុពលភាព ហើយអ្នកកាន់កាប់មិនបានសុំបន្តសុពលភាពត្រឹមត្រូវតាមនីតិវិធីជាធរមាន

–រាល់ការកាន់កាប់ដីរដ្ឋលើសពីទំហំ ឬ ខុសទីតាំងដែលកំណត់ក្នុងលិខិតអនុញ្ញាត ឬ កិច្ចសន្យាឲ្យប្រើប្រាស់

–រាល់ការផ្ទេរសិទ្ធិប្រើប្រាស់ដីរដ្ឋ ដោយបំពានលក្ខខណ្ឌក្នុងលិខិតអនុញ្ញាត ឬ កិច្ចសន្យា

–រាល់ការផ្ទេរបំប្លែងការកាន់កាប់ដីរដ្ឋ ទៅជាកម្មសិទ្ធិឯកជនដោយខុសច្បាប់ មានជាអាទិ៍ការបន្លំធ្វើបណ្ណកម្មសិទ្ធិលើដីសម្បទានសេដ្ឋកិច្ច ឬ លើដីដែលទទួលបានត្រឹមតែការអនុញ្ញាតឲ្យប្រើប្រាស់ ឬ ធ្វើអាជីវកម្ម ឬ ការបំប្លែងដីដែលត្រូវបានកំណត់ជាដីសាធារណៈរបស់រដ្ឋ។[6]

## ផ្នែកទី២ វិធានការទប់ស្កាត់ការកាន់កាប់ដីខុសច្បាប់

### កថាខណ្ឌទី១ ការដកហូតដីរដ្ឋមកវិញ

ដោយសារដីរដ្ឋច្រើនប្រភេទ ដូចនេះនីតិវិធីនៃការទាមទារ យកដីរដ្ឋមកវិញក៏មានលក្ខណៈផ្សេងគ្នាទៅតាមនោះដែរៈ

– ចំពោះដីដែលចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីជាដីរដ្ឋរួចហើយៈ អាជ្ញាធរកាន់កាប់ដីរដ្ឋត្រូវទាមទារដីរដ្ឋមកវិញ ដោយត្រូវចេញលិខិតទាមទារដែលមានបញ្ជាក់ពី ក្បាលដី ទីតាំងដី និងប្លង់បង្ហាញទីតាំងក្បាលដី ឈ្មោះអ្នកកាន់កាប់ដីរដ្ឋបច្ចុប្បន្ន និងទុករយៈពេល ៣០ថ្ងៃសម្រាប់ឆ្លើយ តបមកអាជ្ញាធរវិញ បើករណី ការឆ្លើយតមកមិនយល់ព្រមប្រគល់ដីរដ្ឋវិញ ឬ មានការប្តឹងតវ៉ាណាមួយ អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវធ្វើលិខិតជូនទៅមេឃុំ ចៅសង្កាត់ និង អភិបាលស្រុកខណ្ឌដោយលិខិតនោះត្រូវមានកំណត់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃការជួបពិភាក្សាសម្របសម្រួល ព្រមទាំងភ្ជាប់នូវច្បាប់ចម្លងនៃលិខិតឆ្លើតប ឬ ពាក្យប្តឹងតវ៉ានោះ។[7]

– ចំពោះដីដែលមានក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យរដ្ឋ និង មិនទាន់បញ្ចូលក្នុងបញ្ជីក្នុងបញ្ជីសារពើភ័ណ្ឌ អាជ្ញាធរកាន់កាប់ដីត្រូវចេញលិខិតទាមទារយកដីរដ្ឋមកវិញ ដោយបញ្ជាក់ទីតាំងក្បាលដី ប្លង់បង្ហាញទីតាំងក្បាលដី ទំហំប្រហាក់ប្រហែលនៃក្បាលដី ពត៌មានអំពីព្រំប្រទល់ប្រហាក់

[6] សារាចរលេខ ០២សរ ស្តីពី ការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ទំព័រ ៩៣៧

[7] សារាចរលេខ ០២សរ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ចំនុច ២.១ និង ២.៦ ទំព័រ ៩៣៨ ដល់ ៩៣៩

ប្រហែលនៃក្បាលដី ឈ្មោះអ្នកកាន់កាប់ដីបច្ចុប្បន្ន រយៈពេលឆ្លើយតប ឬ ប្ដឹងតវ៉ាដោយអ្នកមានផលប្រយោជន៍ផ្សេងៗលើក្បាលដីនោះ។[8]

– ចំពោះដីព្រៃឈើរបស់រដ្ឋដែលយកមកធ្វើជាកម្មសិទ្ធិ រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវបទបញ្ជាជាបន្ទាន់ឲ្យអភិបាលខេត្ត ក្រុង ប្រើអំណាចរដ្ឋ ចេញដីកាជាបន្ទាន់ក្នុងការដកហូតដីព្រៃឈើគ្រប់ប្រភេទមកវិញមកទុកជាទ្រព្យសម្បត្តិរដ្ឋវិញ ហើយដីកានោះត្រូវកំណត់រយៈពេល ៣០ថ្ងៃដើម្បីឲ្យគេធ្វើការប្ដឹងតវ៉ា។[9]

## ➢ គោលនយោបាយចំពោះអ្នកកាន់កាប់ដីរដ្ឋដោយខុសច្បាប់

នៅពេលដែលរដ្ឋបានទាមទារមកវិញនូវដីរដ្ឋ អ្នកដែលកាន់កាប់ដីរដ្ឋខុសច្បាប់ គ្មានសិទ្ធិទាមទារសំណង ហើយអាចនឹងប្រឈមមុខទទួលទោសទណ្ឌ ប៉ុន្តែចំពោះគ្រួសារក្រីក្រ ឬ ខ្វះដីអាចផ្ដល់ការអនុគ្រោះក្នុងការទទួលដី ដែលមានទំហំសមស្របដើម្បីប្រកបរបរចិញ្ចឹមជីវិត និង/ឬស្នាក់នៅ។[10]

## កថាខណ្ឌទី២ ការចុះបញ្ជីដី

ដោយយោងតាមច្បាប់ភូមិបាលឆ្នាំ ២០០១ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និង សំណង់ បានតម្រូវឲ្យមានការចុះបញ្ជីដីធ្លី ហើយការចុះបញ្ជីដីធ្លី គឺមានចែកចេញជាការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និង ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ។[11]

ក្រោយឆ្នាំ ២០០១ មានការអនុវត្តជាបន្តបន្ទាប់ ដោយបង្កើតឲ្យមានការចុះបញ្ជីដីបំពេញបន្ថែម តាមសារាចរណ៍លេខ ០៦សណន, ០៥ ឧសភា២០០៦។

ការចុះបញ្ជីដី គឺធ្វើឡើងដើម្បីឲ្យប្រជាជនទទួលបានភាពជាម្ចាស់កម្មសិទ្ធិក្នុងការកាន់កាប់លើដី ត្រឹមត្រូវតាមច្បាប់ និងមានលក្ខណសម្បត្តិគ្រប់គ្រាន់ឲ្យមានការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីសម្រាប់ធានាសិទ្ធិពេញលេញតាមផ្លូវច្បាប់។

[8] សារាចរលេខ ០២សរ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ចំនុច៣ និង ៤ ទំព័រ ៩៤០ ដល់ ៩៤២

[9] បទបញ្ជាលេខ ០១បប ស្ដីពីការទប់ស្កាត់ការកាន់កាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកមកធ្វើជាកម្មសិទ្ធិ ចំនុច ១ និង ២ ទំព័រ ៨២៧

[10] សារាចរលេខ ០២សរ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់ ចំនុច៦.១ និង ៦.២ ទំព័រ ៩៤៥

[11] មាត្រា ២២៩ ច្បាប់ភូមិបាល ឆ្នាំ ២០០១

# សេចក្ដីសន្និដ្ឋាន

សរុបសេចក្ដីមក ច្បាប់របស់ប្រទេសកម្ពុជា បានចែងយ៉ាងច្បាស់លាស់អំពីការកាន់កាប់ដីរបស់បុគ្គលនីមួយៗ ដើម្បីបញ្ចៀសរាល់ជំលោះ និង ការរំលោភបំពានផ្សេងៗដែលអាចនឹងកើតមានជាយថាហេតុ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនកម្ពុជាភាគច្រើន នូវមានកង្វះខាតច្រើនក្នុងការយល់ដឹងអំពីបញ្ហាផ្នែកច្បាប់ដែលទាក់ទិននឹងការកាន់កាប់ដីជាកម្មសិទ្ធិស្របច្បាប់ រួមជាមួយគ្នានេះ ពួកគាត់នៅតែមិនបានដឹងច្បាស់ថាទីតាំងដីនៅកន្លែងណាដែលជាកម្មសិទ្ធិរបស់រដ្ឋ ដោយសំអាងថា គាត់បានរស់នៅទីតាំងនោះយូរណាស់មកហើយ។ ម្លោះហើយ ធ្វើឲ្យរដ្ឋចាត់ទុកថា នោះជាការកាន់កាប់ដីឯកជន ឬ ដីរដ្ឋខុសច្បាប់។ ម្យ៉ាងទៀត ទោះបីជា រដ្ឋបានផ្ដល់ឲ្យនូវកម្មសិទ្ធិលើការកាន់កាប់អចលវត្ថុ ឬ ចលនវត្ថុ ក៏រដ្ឋនៅកំរិតពីកម្មសិទ្ធិដែលជារបស់រដ្ឋ សំរាប់បំរើផលប្រយោជន៍សាធារណៈ។ ចំពោះការកាន់កាប់ដីដែលទុកថាស្របច្បាប់ បានផ្ដល់ឲ្យអ្នកកាន់កាប់ដីនូវសិទ្ធិ និង កាតព្វកិច្ច និងអាចចាត់ចែងទៅលើដីនោះបាន។ ដូចនេះហើយ ក្នុងគោលបំណងចៀសវាងមានការទន្ទ្រានដីពីសំណាក់ជនដ៏ទៃ រដ្ឋក៏បានបង្កើតឲ្យមានច្បាប់ និង ការអនុវត្តផ្សេងៗទៅតាមនីតិវិធីច្បាប់សំរាប់គ្រប់គ្រងទៅលើបញ្ហានេះ ហើយរដ្ឋចាត់វិធានការណ៍ផ្សេងៗ ក្នុងការរកដំណោះស្រាយណាមួយដ៏ល្អប្រសើរសំរាប់ប្រជាជន ពោលគឺ ក្នុងករណីដែលប្រជាជនចូលកាន់កាប់ដីរដ្ឋ ដែលចាត់ទុកថាខុសច្បាប់នោះ រដ្ឋមាននីតិវិធីក្នុងការទាមទារយកមកវិញនូវដីរដ្ឋ ដោយសន្តិវិធី ដោយជូនដំណឹងនោះទៅប្រជាជនមុនសិនមុននឹងធ្វើការដកហូតដីមកវិញ ក៏ប៉ុន្តែប្រសិនបើប្រជាជននៅតែចចេសមិនព្រមប្រគល់ដីនោះមកវិញ រដ្ឋក៏មានវិធានការផ្សេងទៀតដែរ។ ឯចំពោះដីឯកជនវិញ ចំពោះកម្មសិទ្ធិករ ដែលមានកម្មសិទ្ធិលើដីនោះ ត្រូវទៅចុះបញ្ជីដីឲ្យបានត្រឹមត្រូវទៅតាមច្បាប់ដែលកំណត់ ដើម្បីងាយស្រួលកំណត់ថា ដីនោះមានម្ចាស់រួចហើយ។

# អនុសាសន៍

តាមរយៈការសិក្សាស្វែងយល់ និង ស្រាវជ្រាវនូវប្រធានបទទាក់ទាក់ដល់វិធានការ និងការទប់ស្កាត់កុំឲ្យមានកាន់កាប់ដីខុសច្បាប់នៅកម្ពុជា កន្លងមក បានបង្កើននូវចំណេះដឹងជាច្រើនដល់យើងខ្ញុំទាំងអស់គ្នា។ យើងខ្ញុំយល់ថា ប្រជាជននៅកម្ពុជាសព្វថ្ងៃនេះ ភាគច្រើនចំណេះដឹងនៅមានកម្រិតទាបនៅឡើយទាក់ទិននឹងបញ្ហាដីធ្លី ជាហេតុដែលធ្វើពួកគេបានចូលទៅកាន់កាប់លើដីធ្លីទាំងនោះដោយខុសច្បាប់ទាំងមិនដឹងខ្លួន រួមទាំងដីរដ្ឋមួយចំនួនខ្លះផងដែរ។ ចំពោះបញ្ហាទាំងអស់នេះយើងខ្ញុំក៏បានលើកឡើងនូវទស្សនៈមួយចំនួនសំរាប់ធ្វើការទប់ស្កាត់ការរីករាលដាលទង្វើទាំងអស់ដើម្បីឲ្យសង្គមទទួលបានសុខសន្តិភាព និងសណ្តាប់ធ្នាប់ល្អ ដាក់ជូនដល់រដ្ឋាភិបាលទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ជាដំបូង ការធ្វើចំណាត់ថ្នាក់ និង ការអត្តសញ្ញាណកម្មទាំងដីរដ្ឋ និង ដីឯកជនជាកត្តាមួយដែលមិនអាចខ្វះបាន ព្រោះនីតិវិធីបែបនេះ ផ្តល់ឲ្យរដ្ឋមានភាពងាយស្រួល ដោយពុំចាំបាច់ស្មុគស្មាញរឿងពាក់ព័ន្ធវិវាទដីធ្លី រួមទាំងប្រជាជនទូទាំងប្រទេសបានដឹង និង បានឮ គ្រប់ៗគ្នា ថាតើ ទីកន្លែងណា ឬ តំបន់ណាជាដីអាចកាន់កាប់បាន ហើយដីណាមិនអាចកាន់កាប់បាន។ ចំណុចសំខាន់មួយទៀត គឺថា រដ្ឋគួរធ្វើយ៉ាងណាដើម្បីពង្រឹងឲ្យមានការផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ និងមន្ត្រីថ្នាក់ក្រោមជាតិ ហើយការផ្សព្វផ្សាយនោះទៀតសោត ក៏ត្រូវតែប្រព្រឹត្តទៅឲ្យកាន់តែមានប្រសិទ្ធភាពផងដែរ ដូចជា ផ្តល់ឲ្យមានសិក្ខាសាលាទាក់ទងនឹងដីធ្លីដោយវាគ្មិនដែលមានជំនាញ។ មួយវិញទៀត ការគ្រប់គ្រងដីរបស់អាជ្ញាធរមូលដ្ឋាន ក៏នូវមានភាពខ្វះចន្លោះច្រើនដោយហេតុថា ពួកគាត់មិនបានស្វែងយល់ពីបញ្ហាច្បាប់ឲ្យបានច្បាស់លាស់ និងមិនបានចាត់វិធានការដែលឲ្យប្រជាជនមករស់នៅច្រើនលើដីនោះ ជាបញ្ហាពិបាកក្នុងការរកដំណោះស្រាយផ្លាស់ប្តូរទីលំនៅឲ្យពួកគេ នៅពេលដែលដីនោះជាដីរដ្ឋ។

យើងខ្ញុំសង្ឃឹមថា ទស្សនៈនៃការទប់ស្កាត់ការកាន់កាប់ដីធ្លីដោយខុសច្បាប់ ដែលបានលើកឡើងដូចខាងដើម នឹងអាចឲ្យរដ្ឋាភិបាលយកមកពិចារណា ដើម្បីអនុវត្តនូវចំណុចទាំងអស់ សំរាប់ប្រយោជន៍ប្រជាជន និង ប្រយោជន៍ជាតិ។

## គន្លនិទ្ទេស

១. ច្បាប់ភូមិបាល ចុះថ្ងៃទី ៣០ សីហា ២០០១

២. សារាចរ លេខ ០២សរ ចុះថ្ងៃទី ២៦ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពី ការកាន់កាប់ដីរដ្ឋដោយខុសច្បាប់

៣. បទបញ្ជា លេខ ០១បប ចុះថ្ងៃទី ១០ ឧសភា ២០០៦ ស្តីពីការទប់ស្កាត់ការកាន់កាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកមកធ្វើជាកម្មសិទ្ធិ